# ជំពូកទី៧

# ផែនការគ្រប់គ្រងបរិស្ថាន

Draft

# ជំពូកទី ៧
# ផែនការគ្រប់គ្រងបរិស្ថាន

## ៧.១ សេចក្តីផ្តើម

ផែនការគ្រប់គ្រងបរិស្ថាន Environmental Management Plan (EMP) គឺជាផែនការមួយដែលត្រូវរៀបចំឡើងដោយម្ចាស់គំរោង ក្រោមការចុះត្រួតពិនិត្យពីស្ថាប័នដែលមានការពាក់ព័ន្ធទៅនឹងគំរោងស្នើសុំ ដើម្បីធ្វើការត្រួតពិនិត្យនៅគ្រប់ដំណាក់កាលរបស់គំរោង ក្នុងគោលដៅកាត់បន្ថយឬបញ្ចៀសហេតុប៉ះពាល់ដែលអាចនឹងកើតមានឡើង។ ផែនការគ្រប់គ្រងបរិស្ថានអនុវត្តឡើង ដើម្បីធ្វើការតាមដានទៅលើការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមានដែលបានលើកឡើងនៅក្នុងជំពូកទី ៦ ដើម្បីអោយប្រាកដថារាល់វិធានការទាំងអស់ដែលបានលើកឡើងត្រូវបានអនុវត្តន៍ដោយម្ចាស់គំរោងនៅរាល់ដំណាក់កាលដែលគេបានប៉ាន់ប្រមាណថាមានហេតុប៉ះពាល់កើតឡើងដោយសារសកម្មភាពនៃគំរោង។ ផែនការគ្រប់គ្រងបរិស្ថានត្រូវកំណត់ឱ្យបានច្បាស់លាស់ទៅលើទីតាំង ដែលត្រូវត្រួតពិនិត្យរយៈការតាមដាន និងសមាសភាពអ្នកចូលរួមត្រួតពិនិត្យ។

Draft

## ៧.២ សមាសភាពក្រុមត្រួតពិនិត្យ

ការអង្កេតតាមដាន ត្រូវធ្វើឡើងជាប្រចាំដោយមានខាងក្រុមហ៊ុនវិនិយោគផ្ទាល់ជាអ្នកទទួលត្រួតពិនិត្យ។ ហើយការត្រួតពិនិត្យដោយក្រុមអន្តរក្រសួងក៏ត្រូវបានធ្វើឡើងផងដែរ តាមពេលវេលាដែលបានកំណត់ក្នុងតារាង សំរាប់ការចុះត្រួតពិនិត្យ។ ប៉ុន្តែក្នុងករណីមានការប្រែប្រួលខ្លាំងចំពោះស្ថានភាពបរិស្ថានក្នុងតំបន់គំរោង ក្នុងពេលណាមួយដែលមិនទាន់ដល់ពេលដែលអន្តរក្រសួងចុះទៅ ខាងក្រុមហ៊ុនត្រូវធ្វើការរាយការណ៍ជាបន្ទាន់ទៅអោយស្ថាប័នជំនាញ ដើម្បីធ្វើការចុះត្រួតពិនិត្យ និងចាត់វិធានការណ៍ទប់ស្កាត់អោយបានទាន់ពេលវេលា។

សកម្មភាពត្រួតពិនិត្យ និងឃ្លាំមើល ធ្វើឡើងដោយក្រុមការងារអន្តរក្រសួង និងអាជ្ញធរដែនដីដូចមានសមាសភាពខាងក្រោម :

- តំណាងក្រសួងបរិស្ថាន (នាយកដ្ឋានអភិរក្ស និងការពារធម្មជាតិ, នាយកដ្ឋានអង្កេតពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងនាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន)
- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- តំណាងក្រសួងធនធានទឹក និងឧតុនិយម

- តំណាងសាលាខេត្តមណ្ឌលគិរី
- តំណាងមន្ទីរបរិស្ថានខេត្តមណ្ឌលគិរី
- តំណាងសាលាស្រុកពេជ្រាដា ស្រុកអូររាំង
- តំណាងសាលាឃុំប៊ូស្រា ឃុំដាក់ដាំ
- តំណាងក្រុមហ៊ុនវិនិយោគ

សូមបញ្ជាក់ថាសមាសភាពខាងលើនេះ គឺស្ថិតនៅក្រោមការចង្អុលបង្ហាញ និងណែនាំដោយក្រសួងបរិស្ថាន ។

## ៧.៣ កម្មវិធីត្រួតពិនិត្យបរិស្ថាន

កម្មវិធីត្រួតពិនិត្យបរិស្ថាន Environmental Monitoring Programme គឺជាកម្មវិធីមួយដែលម្ចាស់ក្រុមហ៊ុនត្រូវធ្វើការត្រួតពិនិត្យដោយខ្លួនឯងនៅគ្រប់វដ្តជីវិតរបស់គំរោង ដើម្បីចូលរួមកាត់បន្ថយនូវហេតុប៉ះពាល់ដែលអាចកើតមានឡើងដែលបានលើកឡើងក្នុងជំពូកខាងដើម ដើម្បីចូលរួមចំណែកការថែរក្សានូវធនធានបរិស្ថាន ក៏ដូចជាការអនុវត្តន៍នូវកិច្ចដំណើរការគំរោងឱ្យមានស្ថេរភាព។ លទ្ធផលនៃការត្រួតពិនិត្យនេះ ម្ចាស់គំរោងនឹងបញ្ជូនរបាយការណ៍ទៅអោយក្រសួងបរិស្ថានរៀងរាល់០៦ខែម្តង ។

កម្មវិធីត្រួតពិនិត្យបរិស្ថានត្រូវធ្វើឡើងនៅក្នុងដំណាក់កាលរបស់គំរោង ក្នុងនោះរួមមាន :

១. ដំណាក់កាលឈូសឆាយដី និងការសាងសង់ :ការរៀបចំការដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធ និងសាងសង់រោងចក្រ

២. ដំណាក់កាលប្រតិបត្តិគំរោង : ការឈូសឆាយដីសំរាប់ធ្វើការដាំដុះ ការថែទាំ ការប្រមូលផល និងធ្វើការដាំដុះឡើងវិញ

៣. ដំណាក់កាលបញ្ចប់គំរោង : ប្រគល់ទីតាំងដីសម្បទានសេដ្ឋកិច្ចទៅឱ្យរាជរដ្ឋាភិបាលវិញ ។

### ៧.៣.១ ដំណាក់កាលឈូសឆាយដី និងការសាងសង់

ការត្រួតពិនិត្យធនធានបរិស្ថានសង្គម នៅក្នុងដំណាក់កាលនេះសំរាប់គំរោងវិនិយោគដាំដំណាំកសិ-ឧស្សាហកម្ម (ដាំដើមឈើកៅស៊ូ និងប្រភេទឈើផ្សេងៗទៀត) នៅឃុំប៊ូស្រា ស្រុកពេជ្រាដា ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី របស់ក្រុមហ៊ុន SETHIKULA Co., Ltd. ដើម្បីពិនិត្យមើលហេតុប៉ះពាល់ បរិស្ថានអវិជ្ជមាន ដែលកើតមានដោយសារសកម្មភាពនានានៅក្នុងដំណាក់កាលនេះ ។

### ៧.៣.២ ដំណាក់កាលប្រតិបត្តិគំរោង

ដំណាក់កាលប្រតិបត្តិគំរោង គឺជាដំណាក់កាលដែលបង្កឱ្យមានហេតុប៉ះពាល់បរិស្ថានអវិជ្ជមានខ្លាំងជាងគេ ដោយសារគំរោងមានរយៈពេលវែងដែលសកម្មភាពគំរោងមួយចំនួនអាចធ្វើឱ្យមានឥទ្ធិពលមិនល្អចំពោះបរិស្ថាន និងការរស់នៅ

របស់សហគមន៍មូលដ្ឋានដែលរស់នៅក្នុង និងក្បែរទីតាំងគំរោង ហេតុនេះការត្រួតពិនិត្យត្រូវធ្វើឡើងជាចាំបាច់ក្នុងដំណាក់កាលនេះ ។

### ៧.៣.៣ ដំណាក់កាលបញ្ចប់គំរោង

ការត្រួតពិនិត្យបរិស្ថានក្នុងពេលបញ្ចប់គំរោង គឺដើម្បីប្រមើមើលឱ្យឃើញថា ហេតុប៉ះពាល់បរិស្ថានក្នុងដំណាក់កាលនេះត្រូវបានលុបបំបាត់ ឬកាត់បន្ថយមុនគំរោងបញ្ឈប់ដំណើរការ ។ ការត្រួតពិនិត្យនេះធ្វើការតាមដានទៅលើការអនុវត្តវិធានការកាត់បន្ថយដែលចាំបាច់ដើម្បី :

- លុបបំបាត់ ឬកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានដល់ធនធានបរិស្ថាន និងសង្គម ដែលមាននៅក្នុង និងជុំវិញទីតាំងគំរោង
- ជួសជុល ឬស្តារឡើងវិញនូវធនធានបរិស្ថាន និងរចនាសម្ព័ន្ធនៅជុំវិញ ដែលទទួលរងការខូចខាតដោយសារសកម្មភាពគំរោង
- ការពារ ឬគ្រប់គ្រងសំណល់គ្រោះថ្នាក់ដែលអាចបោះចោលក្នុងទីតាំងនោះ ។

កម្មវិធីត្រួតពិនិត្យបរិស្ថានសំខាន់ៗមានបង្ហាញជូននៅក្នុងតារាង ៧.១ ។

Draft

## តារាង ៧.១ : កម្មវិធីត្រួតពិនិត្យបរិស្ថាន

| ...ឈរ | ធនធានបរិស្ថាន | ទីតាំងត្រួតពិនិត្យ | ការត្រួតពិនិត្យ | ស្ថាប័នទទួលខុសត្រូវ | រយៈកាលតាមដាន |
|---|---|---|---|---|---|
| ១. | ធនធានរូបសាស្ត្រ | | | | |
| | ...បណ្ណានដី | ▪ ទីតាំងឈូសឆាយតាមអនុតំបន់នីមួយៗ<br>▪ កន្លែងរៀបចំថ្នាលកូនកៅស៊ូ<br>▪ តំបន់ទីជំរាលនៅក្នុងតំបន់គំរោង | ▪ ការឈូសឆាយពង្រាបដី ធ្វើផ្លូវ និងការដ្ឋាន<br>▪ រៀបចំថ្នាលបណ្តុះកូនកៅស៊ូ<br>▪ ឈូសឆាយបែងចែកអនុតំបន់ | ▪ ក្រុមហ៊ុនវិនិយោគ | ▪ ដំណាក់កាលសាងសង់ រយៈពេល ០១ខែ/ដង<br>▪ ដំណាក់កាលប្រតិបត្តិ រយៈពេល ០៣ខែ/ដង<br>▪ ដំណាក់កាលបញ្ចប់គំរោង មួយដង |
| | ការហូរច្រោះដី និង ...ណភាពដី | ▪ កន្លែងទុកដាក់សំណល់រឹង-រាវ<br>▪ឃ្លាំងស្តុកប្រេង និង ថ្នាលដាំដុះដែលមានប្រើប្រាស់ជីកសិកម្ម<br>▪ ព្រៃឈើនៅតាមមាត់អូរដែលរក្សាទុក<br>▪ កន្លែងឈូសឆាយនៅតាមអនុតំបន់<br>▪ តំបន់ភ្នំ និងខ្ពង់រាបដែលងាយរងការហូរច្រោះ | ▪ ការគ្រប់គ្រងសំណល់រឹង-រាវ<br>▪ ការប្រើប្រាស់ និងការទុកដាក់ប្រេង ជីកសិកម្ម<br>▪ ការដាំដុះរបស់ ( អនុវត្តតាមផែនការមេដែលបានស្នើឡើង)<br>▪ ព្រៃឈើតាមមាត់អូរ ដែលរក្សាទុក<br>▪ សកម្មភាពឈូសឆាយ | ▪ ក្រុមហ៊ុនវិនិយោគ | ▪ ដំណាក់កាលសាងសង់ រយៈពេល ០១ខែ/ដង<br>▪ ដំណាក់កាលប្រតិបត្តិ រយៈពេល ០៣ខែ/ដង<br>▪ ដំណាក់កាលបញ្ចប់គំរោង មួយដង |
| | ...លសាស្ត្រ និង ...ណភាពទឹកលើដី | ▪ ព្រៃឈើនៅតាមមាត់អូរក្នុងទីតាំងគំរោង<br>▪ កន្លែងទុកសំណល់រឹង-រាវ<br>▪ ឃ្លាំងស្តុកប្រេង ជីកសិកម្ម និងថ្នាលបណ្តុះកូនកៅស៊ូ | ▪ ព្រៃឈើតាមមាត់អូរ ដែលរក្សាទុក<br>▪ ការទុកដាក់សំណល់រឹង-រាវក្នុងតំបន់គំរោង<br>▪ ការប្រើប្រាស់ និងការទុកដាក់ជីកសិកម្ម<br>▪ ចរន្តទឹកហូរ | ▪ ក្រុមហ៊ុនវិនិយោគ | ▪ ដំណាក់កាលសាងសង់ រយៈពេល ០១ខែ/ដង<br>▪ ដំណាក់កាលប្រតិបត្តិ រយៈពេល ០៣ខែ/ដង |

Draft

| | | | | |
|---|---|---|---|---|
| | ▪ សណ្ឋានដីទីជំរាលនៅក្នុងតំបន់គំរោង | ▪ វិភាគគុណភាពទឹក | | ▪ ដំណាក់កាលបញ្ចប់គំរោងមួយដង |
| គុណភាពទឹកក្រោមដី | ▪ កន្លែងស្តុក និងថ្នាលដាំដុះដែលមានប្រើប្រាស់ជីកសិកម្ម<br>▪ កន្លែងទុកដាក់សំណល់រឹង-រាវ | ▪ ការទុកដាក់សំណល់រឹង-រាវ<br>▪ ការទុកដាក់ និងការប្រើប្រាស់ជីកសិកម្ម<br>▪ ការវិភាគគុណភាពទឹក | ▪ ក្រុមហ៊ុនវិនិយោគ | ▪ ដំណាក់កាលសាងសង់ រយៈពេល ០១ខែ/ដង<br>▪ ដំណាក់កាលប្រតិបត្តិ រយៈពេល ០៣ខែ/ដង<br>▪ ដំណាក់កាលបញ្ចប់គំរោងមួយដង |
| គុណភាពខ្យល់ | ▪ ម៉ាស៊ីនភ្លើង<br>▪ កន្លែងទុកដាក់សំណល់រឹង-រាវផ្សេងៗទៀត<br>▪ ម៉ាស៊ីនមួយចំនួន ( ត្រាក់ទ័រ....) | ▪ គុណភាពខ្យល់ក្នុងតំបន់គំរោង<br>▪ ការបញ្ចេញផ្សែងរបស់គ្រឿងចក្រ និងម៉ាស៊ីនភ្លើង | ▪ ក្រុមហ៊ុនវិនិយោគ | ▪ ដំណាក់កាលសាងសង់ រយៈពេល ០១ខែ/ដង<br>▪ ដំណាក់កាលប្រតិបត្តិ រយៈពេល ០៣ខែ/ដង<br>▪ ដំណាក់កាលបញ្ចប់គំរោងមួយដង |
| សំលេង និងរំញ័រ | ▪ ម៉ាស៊ីនភ្លើង និងគ្រឿងចក្រនានាដែលបំរើបំរាស់ក្នុងគំរោង | ▪ សម្លេង និងរំញ័ររបស់គ្រឿងចក្រក្នុងតំបន់គំរោង<br>▪ ល្បឿនបើកបរ<br>▪ ពេលវេលាធ្វើការ<br>▪ គ្រឿងចក្រសំរាប់ឈូសឆាយ | ▪ ក្រុមហ៊ុនវិនិយោគ | ▪ ដំណាក់កាលសាងសង់ រយៈពេល ០១ខែ/ដង<br>▪ ដំណាក់កាលប្រតិបត្តិ រយៈពេល ០៣ខែ/ដង<br>▪ ដំណាក់កាលបញ្ចប់គំរោងមួយដង |
| ២. ធនធានជីវសាស្ត្រ | | | | |

Draft

| | | | | |
|---|---|---|---|---|
| ធនធានព្រៃឈើ និងជម្រកសត្វព្រៃ | ▪ ព្រៃឈើនៅតាមមាត់អូរ និងព្រៃដែលរក្សាទុក<br>▪ តំបន់ដែលមានសត្វព្រៃឆ្លងកាត់<br>▪ កន្លែងដាក់ប្រព័ន្ធការពារភ្លើងព្រៃតាមអនុតំបន់<br>▪ ព្រៃក្នុងតំបន់រក្សាទុកដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ▪ ការលួចឆាយ និងការដាំដុះ<br>▪ ព្រៃឈើតាមមាត់អូរ ដែលរក្សាទុក<br>▪ ស្ថានភាពព្រៃដែលត្រូវកាត់ចេញពីការអនុវត្តគំរោង<br>▪ ភ្លើងព្រៃ និងប្រព័ន្ធផ្លូវការពារភ្លើងព្រៃ | ▪ ក្រុមហ៊ុនវិនិយោគ | ▪ ដំណាក់កាលសាងសង់ រយៈពេល ០១ខែ/ដង<br>▪ ដំណាក់កាលប្រតិបត្តិ រយៈពេល ០៣ខែ/ដង<br>▪ ដំណាក់កាលបញ្ចប់គំរោង មួយដង |
| ជីវៈចំរុះក្នុងទឹក | ▪ ព្រៃឈើនៅតាមមាត់អូរ និងទឹកអូរ ក្នុងទីតាំងគំរោង<br>▪ កន្លែងទុកដាក់សំណល់រឹង-កន្លែងបង្ហូរសំណល់រាវ<br>▪ ព្រៃក្នុងតំបន់រក្សាទុកដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ▪ ការគ្រប់គ្រងសំណល់រឹង-រាវរបស់គំរោង<br>▪ ព្រៃឈើតាមមាត់អូរ ដែលរក្សាទុក<br>▪ គុណភាពទឹកនៅក្នុងតំបន់គំរោង | ▪ ក្រុមហ៊ុនវិនិយោគ | ▪ ដំណាក់កាលសាងសង់ រយៈពេល ០១ខែ/ដង<br>▪ ដំណាក់កាលប្រតិបត្តិ រយៈពេល ០៣ខែ/ដង<br>▪ ដំណាក់កាលបញ្ចប់គំរោង មួយដង |
| ៣. ធនធានសេដ្ឋកិច្ច-សង្គម | | | | |
| ការរស់នៅរបស់សហគមន៍មូលដ្ឋាន | ▪ ព្រៃឈើនៅតាមមាត់អូរក្នុងទីតាំងគំរោង និងទឹកអូរដែលប្រើប្រាស់ដោយប្រជាជន<br>▪ ព្រៃឈើដែលត្រូវកាត់ចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ▪ ព្រៃឈើដែលប្រជាជនប្រមូលអនុផល<br>▪ ព្រៃឈើនៅតាមមាត់អូរ ដែលរក្សាទុក<br>▪ គុណភាពទឹកអូរដែលប្រើប្រាស់ដោយប្រជាជននៅក្នុង និងក្បែរតំបន់គំរោង<br>▪ ការលួចឆាយដែលធ្វើឱ្យប៉ះពាល់ដល់ព្រៃតំណមដែលជាប្រពៃណី ទំនៀមទំលាប់របស់សហគមន៍មូលដ្ឋាន<br>▪ ទំនៀមទំលាប់ប្រពៃណី សាសនារបស់ | ▪ ក្រុមហ៊ុនវិនិយោគ | ▪ ដំណាក់កាលសាងសង់ រយៈពេល ០១ខែ/ដង<br>▪ ដំណាក់កាលប្រតិបត្តិ រយៈពេល ០៣ខែ/ដង<br>▪ ដំណាក់កាលបញ្ចប់គំរោង មួយដង |

Draft

| | | | | |
|---|---|---|---|---|
| សហគមន៍មូលដ្ឋាន | | | | |
| ការប្រើប្រាស់ដី | ▪ ការដ្ឋានឈូសឆាយ<br>▪ ទំហំ និងព្រំប្រទល់របស់គំរោង | ▪ ការឈូសឆាយរបស់គំរោងដែលធ្វើឱ្យប៉ះពាល់ដល់ការប្រើប្រាស់ដីសាធារណៈ និងដីរបស់ប្រជាជន<br>▪ ការដោះស្រាយវិវាទីដីធ្លីនានា | ▪ ក្រុមហ៊ុនវិនិយោគ<br>▪ ប្រជាជនមូលដ្ឋាន | ▪ ដំណាក់កាលសាងសង់ រយ:ពេល ០១ខែ/ដង<br>▪ ដំណាក់កាលប្រតិបត្តិ រយ:ពេល ០៣ខែ/ដង<br>▪ ដំណាក់កាលបញ្ចប់គំរោង មួយដង |
| ការប្រើប្រាស់ទឹក | ▪ ប្រភពទឹកអូរដែលមានក្នុងតំបន់គំរោង<br>▪ កន្លែងទាញយកទឹកមកប្រើប្រាស់របស់គំរោង | ▪ ត្រួតពិនិត្យមើលគុណភាព និងបរិមាណទឹកអូរ ដែលប្រជាពលរដ្ឋប្រើប្រាស់<br>▪ វត្តមានប្រភពទឹកនានា ដែលមានក្នុងគំរោង<br>▪ ព្រៃសងខាងអូរ និងព្រៃរក្សាទុកនានា | ▪ ក្រុមហ៊ុនវិនិយោគ<br>▪ ប្រជាជនមូលដ្ឋាន | ▪ ដំណាក់កាលសាងសង់ រយ:ពេល ០១ខែ/ដង<br>▪ ដំណាក់កាលប្រតិបត្តិ រយ:ពេល ០៣ខែ/ដង<br>▪ ដំណាក់កាលបញ្ចប់គំរោង មួយដង |
| ផ្លូវគមនាគមន៍ និងចរាចរ | ▪ ផ្លូវក្នុងតំបន់គំរោង និងផ្លូវក្នុងភូមិ ដែលគំរោងប្រើសម្រាប់ដឹកជញ្ជូន | ▪ ការធ្វើចរាចរណ៍ និងផ្លាកសញ្ញាចរាចរតាមផ្លូវក្នុងតំបន់គំរោង<br>▪ ការថែទាំនិងជួសជុលផ្លូវក្នុងតំបន់គំរោង | ▪ ក្រុមហ៊ុនវិនិយោគ<br>▪ ប្រជាជនមូលដ្ឋាន | ▪ ដំណាក់កាលសាងសង់ រយ:ពេល ០១ខែ/ដង<br>▪ ដំណាក់កាលប្រតិបត្តិ រយ:ពេល ០៣ខែ/ដង<br>▪ ដំណាក់កាលបញ្ចប់គំរោង១ដង |



Draft

| | | | | |
|---|---|---|---|---|
| សុខមាលភាពសាធារណៈ | ▪ តំបន់គំរោង ពិសេសកន្លែងព្យាបាលក្នុងគំរោង និងស្ថានភាពផ្ទះរស់នៅរបស់បុគ្គលិក-កម្មករក្នុងគំរោង<br>▪ កន្លែងដែលកម្មករបំពេញការងារ | ▪ ការថែរក្សាសុវត្ថិភាពនៅក្នុងតំបន់គំរោង<br>▪ ការប្រើប្រាស់ទឹក និងការហូបចុករបស់កម្មករដែលគំរោងផ្គត់ផ្គង់<br>▪ ស្ថានភាពសុខភាពរបស់បុគ្គលិក-កម្មករគំរោង<br>▪ មើលបរិក្ខារ និងថ្នាំពេទ្យ<br>▪ ការទប់ស្កាត់ជម្ងឺឆ្លង និងជាពិសេសរបៀបការពារខ្លួន ចំពោះជំងឺគ្រុនចាញ់ក្នុងតំបន់គំរោង<br>▪ ឧបករណ៍ការពារសុវត្ថិភាពផ្សេងៗនៅពេលបំពេញការងារ ឧបករណ៍ពន្លត់អគ្គិភ័យ ឧបករណ៍សង្គ្រោះបន្ទាន់ | ▪ មណ្ឌលសុខភាពក្នុងតំបន់គំរោង<br>▪ ក្រុមហ៊ុនវិនិយោគ | ▪ ដំណាក់កាលសាងសង់ រយៈពេល ០១ខែ/ដង<br>▪ ដំណាក់កាលប្រតិបត្តិ រយៈពេល ០៣ខែ/ដង<br>▪ ដំណាក់កាលបញ្ចប់គំរោង១ដង |

## ៧.៤ វិធានការការពារបរិស្ថាន

នៅគ្រប់ដំណាក់កាលនៃគំរោង ក្រុមហ៊ុននឹងរៀបចំកំណត់នូវវិធានការមួយចំនួនដើម្បីធ្វើការទប់ស្កាត់ និងកាត់បន្ថយរាល់ហេតុប៉ះពាល់បរិស្ថានអវិជ្ជមានដែលកើតមានឡើងពីរាល់សកម្មភាពរបស់គំរោង និងដើម្បីធានាការគ្រប់គ្រងធនធានបរិស្ថានក្នុងតំបន់នោះប្រកបដោយប្រសិទ្ធិភាពស្របទៅតាមលក្ខណៈបច្ចេកទេស និងបទដ្ឋានបរិស្ថាន។ ជាមួយគ្នានេះដែរ ក្រុមហ៊ុនធានាឱ្យបាននូវគំរោងអភិវឌ្ឍន៍ប្រកបដោយស្ថេរភាពដែលក្នុងនោះ :

- រៀបចំផ្នែក ឬក្រុមទទួលខុសត្រូវសម្រាប់អនុវត្តផែនការគ្រប់គ្រងបរិស្ថាន
- បំពាក់ឧបករណ៍ការពារសុខភាព/សុវត្ថិភាព
- ការពារ និងបង្កាជម្ងឺរាតត្បាតផ្សេងៗ ជាពិសេសរៀបចំឱ្យមានពេទ្យព្យាបាលពេលមានបញ្ហា
- គ្រប់គ្រងសំណល់រឹង-រាវ និងសំណល់សារធាតុពុលឱ្យបានល្អ
- ធ្វើការអភិរក្សប្រភេទឈើ និងវល្លិ៍សំខាន់ៗ និងសត្វព្រៃដែលធ្លាប់មាននៅតំបន់គំរោង
- ធ្វើការផ្សព្វផ្សាយ និងអប់រំណែនាំពីប្រភេទព្រៃឈើ និងពពួកសត្វព្រៃដែលត្រូវអភិរក្សក្នុងតំបន់គំរោង
- ធ្វើការផ្សព្វផ្សាយ និងអប់រំណែនាំវិធីសាស្ត្រការពារសុខភាព អនាម័យ សុវត្ថិភាពការងារ
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជំនាញក្នុងការត្រួតពិនិត្យមើលទីតាំងគំរោង និងទទួលយកនូវអនុសាសន៍ ដើម្បីធ្វើការកែប្រែបច្ចេកទេសណាមួយដែលជំនាញបានតំរូវ
- ក្រុមហ៊ុនត្រៀមថវិកាមួយផ្នែកតូចដែលបានមកពីប្រាក់ចំណេញសំរាប់មូលនិធិបរិស្ថាន និង សង្គម។ មូលនិធិបរិស្ថានប្រើដើម្បីស្តារបរិស្ថានឡើងវិញទៅតាមតំរូវការជាក់ស្តែងរបស់ក្រសួងបរិស្ថាន។ នឹងចូលរួមចំណែកជាថវិកាក្នុង មូលនិធិឃុំ/សង្កាត់សំរាប់យក ទៅអភិវឌ្ឍន៍នៅតាមភូមិ-សង្កាត់ទៅតាមតំរូវការជាក់ស្តែង ។ដោយឡែកមូលនិធិទាយជ្ជទានបរិស្ថានក្រុមហ៊ុននឹងបង់ប្រចាំឆ្នាំតាមកិច្ចសន្យាការពារបរិស្ថាន

**តារាងទី ៧.២ : តំលៃប៉ាន់ស្មានសំរាប់ការអនុវត្តន៍ EMP និងការត្រួតពិនិត្យតាមដាន**

| កម្មវិធី | សកម្មភាព | ចំនួន | តំលៃ(ដុល្លា) | |
|---|---|---|---|---|
| | | | ឯកតា | សរុប |
| ហេដ្ឋារចនាសម្ព័ន្ធ | រៀបចំគំរោង | ០១ | ១២០.០០០ | ១២០.០០០ |
| | ស្នាក់ការមេ និងកន្លែងបណ្តុះកូនកៅស៊ូ | ០១ | ១២០.០០០ | ១២០.០០០ |
| | ស្នាក់ការរង | ០៥ | ៤០.០០០ | ២០០.០០០ |
| | ប៉មយាមភ្លើង | ១២ | ២.០០០ | ២៤.០០០ |
| | ប៉ុស្តិ៍ល្បាត | ០៩ | ១.៥០០ | ១៣.៥០០ |
| | ប៉ុស្តិ៍សុវត្ថិភាព | ០២ | ២.៥០០ | ៥.០០០ |
| | ប៉ុស្តិ៍សុខភាព | ០១ | ៦០.០០០ | ៦០.០០០ |

Draft

| | | | | |
|---|---|---|---|---|
| | សាលារៀន | ០១ | ១២៥.០០០ | ១២៥.០០០ |
| | ប្រព័ន្ធផ្លូវ (គ.ម) | ៣៨៥ | ១.៧៥៥.១០៨ | ១.៧៥៥.១០៨ |
| សរុប | | | | ២.៤២២.៦០៨ |
| គ្រប់គ្រងតំបន់ទ្រនាប់ | ស្ថានីយ៍ល្បាតអចិន្ត្រៃយ៍ | ០៣ | ៩០០ | ២.៧០០ |
| | អ្នកល្បាត(១០៨ខែ) | ០២/ស្ថានីយ៍ | ១៥០ | ៩៧.២០០ |
| | មធ្យោបាយ និងភស្តុភា | ០១/ស្ថានីយ៍ | ៥០០ | ១.៥០០ |
| សរុប | | | | ១០១.៤០០ |
| ប្រាក់បរិច្ចាកសង្គម និងបរិស្ថាន | មូលនិធិសំរាប់អភិវឌ្ឍន៍សហគមន៍ | ០៩ឆ្នាំ | ១៥.០០០ | ១៣៥.០០០ |
| | មូលនិធិសំរាប់ស្តារបរិស្ថាន | ០៩ឆ្នាំ | ២០.០០០ | ១៨០.០០០ |
| សរុប | | | | ៣១៥.០០០ |
| ការត្រួតពិនិត្យ | LEC (១០៨ខែ) | ០១ | ៣០០ | ៩៧.២០០ |
| | នាយកដ្ឋាន EIA (០៣នាក់) | ០៣ខែម្តង | ១.៥០០ | ៥៤.០០០ |
| | នាយកដ្ឋាន EIA និងគណកម្មការ អន្តរៈក្រសួង | ០៦ខែម្តង | ៥.០០០ | ៩០.០០០ |
| | តេស្តិ៍ | ០៦ខែម្តង | ១.៨០០ | ៣២.៤០០ |
| សរុប | | | | ២៧៣.៦០០ |
| សរុបរួម | | | | ២.៧៩៧.៦០៨ |

## ៧.៥ កម្មវិធីបណ្តុះបណ្តាល

កម្មវិធីបំពាក់បំប៉នក៏ជាផ្នែកសំខាន់មួយនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន ដែលក្រុមហ៊ុននឹងយកចិត្តទុកដាក់ដើម្បីឱ្យដំណើរការរបស់គំរោងទទួលបានជោគជ័យ ។ ដើម្បីធ្វើឱ្យគំរោងនេះមានការអភិវឌ្ឍប្រកបដោយស្ថេរភាពចំបាច់ត្រូវមានធនធានមនុស្ស ដែលមានសមត្ថភាពគ្រប់គ្រាន់សំរាប់បំពេញការងារឱ្យបានរីកចំរើន និងសុក្រឹត្យភាពទាំងការងារបច្ចេកទេស និងការងារបរិស្ថាន ដូច្នេះក្រុមហ៊ុននឹងរៀបចំឱ្យមានវគ្គបំពាក់បំប៉នដល់បុគ្គលិក-កម្មករមួយចំនួនដូចជា ៖

- ផ្តល់ចំណេះដឹងបច្ចេកទេសសំរាប់ប្រើ ឬបញ្ជាគ្រឿងចក្រម៉ាស៊ីនគ្រប់ប្រភេទក្នុងដំណើរការគំរោង
- បំពាក់បំប៉ន និងផ្សព្វផ្សាយពីជំនាញបច្ចេកទេស ច្បាប់ និងលិខិតបទដ្ឋានផ្សេងៗដែលពាក់ព័ន្ធ
- បណ្តុះបណ្តាលដល់កម្មករឱ្យបំពាក់ឧបករណ៍ការពារសុខភាពពេលកំពុងធ្វើការ
- អប់រំកម្មករពីអត្ថប្រយោជន៍នៃធនធានបរិស្ថានសំខាន់ៗដែលមាននៅក្នុងតំបន់គំរោង
- អប់រំពីវិធីសាស្ត្រជួយការពារបរិស្ថានក្នុង និងជុំវិញតំបន់គំរោង
- បំពាក់បំប៉នដល់កម្មករក្នុងការគ្រប់គ្រងសំណល់រឹង-រាវ
- អប់រំដល់កម្មករក្នុងការគ្រប់គ្រងវត្ថុធាតុដើម ដែលជាសារធាតុគីមី សំរាប់ប្រើប្រាស់ក្នុងសង្វាក់ផលិតកម្ម
- អប់រំកម្មករឱ្យយល់ដឹងពីបញ្ហាជំងឺឆ្លងនានា និងវិធីការពារខ្លួនពីជំងឺគ្រុនចាញ់ និងជំងឺអេដស៍ ។